ធ្វើនៅភ្នំពេញ, ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ១៩៩៣

## សេចក្តីសំរេច លេខ ២១ សសរ
## ស្តីពីការបង្កើតគណៈកម្មការសំរាប់ធ្វើការវាយតម្លៃ
## សេចក្តីត្រូវការនៃកងទ័ពជាតិកម្ពុជា

* * *

### រដ្ឋាភិបាលជាតិបណ្តោះអាសន្ន នៃកម្ពុជា

- បានឃើញព្រះរាជក្រឹត្យរបស់សម្តេចព្រះប្រមុខរដ្ឋ ចុះថ្ងៃទី ០២ ខែ កក្កដា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរដ្ឋាភិបាលជាតិបណ្តោះអាសន្ន នៃកម្ពុជា
- យោងតាមកិច្ចព្រមព្រៀង រវាងរដ្ឋាភិបាលជាតិបណ្តោះអាសន្ននៃកម្ពុជានិង រដ្ឋាភិបាល នៃសាធារណរដ្ឋបារាំង អំពីកិច្ចសហប្រតិបត្តិការបច្ចេកទេស ក្នុងវិស័យការពារ ចុះថ្ងៃទី ០៦ ខែ កក្កដា ឆ្នាំ ១៩៩៣

### សំរេច

ប្រការ ១ : បង្កើតគណៈកម្មការសំរាប់ធ្វើការជាមួយ នាយទាហាន សេនាធិការ នៃបេសកកម្ម របស់រដ្ឋាភិបាល នៃសាធារណរដ្ឋបារាំងសំរាប់ធ្វើការវាយតម្លៃ សេចក្តីត្រូវការ នៃកងទ័ពជាតិកម្ពុជា ដែលមានសមាសភាពដូចខាងក្រោម ÷

១- ឯកឧត្តម ឧត្តមសេនីយឯក ទៀ បាញ់ អនុរដ្ឋមន្ត្រីក្រសួងការពារជាតិ ជាសហប្រធាន

២- ឯកឧត្តម ឧត្តមសេនីយឯក ទា ចំរ៉ាត់ អនុរដ្ឋមន្ត្រីក្រសួងការពារជាតិ ជាសហប្រធាន

៣- ឯកឧត្តម ឧត្តមសេនីយឯក កែ គឹមយ៉ាន នាយអគ្គសេនាធិការនៃកងទ័ពជាតិ ជាអនុប្រធាន

៤- លោក ឧត្តមសេនីយឯក ជ៉ាន់ ថៃ នាយករងអគ្គសេនាធិការរងនៃកងទ័ពជាតិ ជាសមាជិក

៥- លោក ឧត្តមសេនីយឯក ប៉ុល សរុទ្ធ អធិការដ្ឋានក្រសួងការពារជាតិ ជាសមាជិក

៦- លោក ឧត្តមសេនីយឯក ក្រូច ឃៀម ខុទ្ទកាល័យក្រសួងការពារជាតិ ជាសមាជិក

៧- លោក ឧត្តមសេនីយឯក ភួង ស៊ីផាន នាយកដ្ឋានបុគ្គលិក ជាសមាជិក

៨- លោក ឧត្តមសេនីយឯកបំរុង ស៊ុំ សំណាង នាយកដ្ឋានសម្ភារ ជាសមាជិក

៩- លោក ឧត្តមសេនីយឯកបំរុង ព្រាប ពាន់ នាយកដ្ឋានកិច្ចការយោធា និង ស៊ីវិល ជាសមាជិក

១០- លោក ឧត្តមសេនីយឯកចំរុង ផាន់ ធួន កងអាកាសចរជាតិកម្ពុជា ជាសមាជិក

១១- លោក ឧត្តមសេនីយឯកចំរុង អ៊ុង សំខាន់ កងនាវាចរជាតិកម្ពុជា ជាសមាជិក

១២- លោក ឧត្តមសេនីយទោ មប់ រឿប ទីប្រឹក្សាសហរដ្ឋមន្ត្រីក្រសួងការពារជាតិ ជាសមាជិក

១៣- លោក ឧត្តមសេនីយទោ ម៉ឹង សំផន នាយកដ្ឋានថវិកា ជាសមាជិក

១៤- លោក ឧត្តមសេនីយទោ លី ដេង ការិយាល័យទី ១ អគ្គសេនាធិការ ជាសមាជិក

១៥- លោក ឧត្តមសេនីយទោ ហ៊ឹង ឡុង នាយកដ្ឋានទាក់ទងអន្តរជាតិ ជាសមាជិក

ប្រការ ២ : គណៈកម្មការនេះ មានភារកិច្ចជួបធ្វើការដោយផ្ទាល់ជាមួយនាយមហាអគ្គសេនាធិការ របស់រដ្ឋាភិបាល នៃសាធារណរដ្ឋបារាំងដែលមកចំពោះបេសកកម្ម សំរាប់ធ្វើការវាយតម្លៃ សេចក្តីត្រូវការក្នុងកងទ័ពជាតិកម្ពុជា ជួយជំរាបមន្ត្រីជាន់ខ្ពស់របស់កម្ពុជា ក្នុងការសិក្សាក្របខ័ណ្ឌទូទៅ បែបបទ និង វិធីរៀបចំរចនាសម្ព័ន្ធនៃកងទ័ពប្រដាប់អាវុធកម្ពុជា ឡើងវិញតាមខ្លឹមសារដែលមានចែងក្នុងកិច្ចព្រមព្រៀង ។

ប្រការ ៣ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងការពារជាតិ អគ្គសេនាធិការ ឯកឧត្តម អស់លោក ដូចមានរាយនាមក្នុងប្រការ ១ ខាងលើ ត្រូវអនុវត្តតាមសេចក្តីសំរេចនេះ ។

សហប្រធាន

ព្រះហស្តលេខា ហត្ថលេខា

ស្តេចក្រុមហ្លួង នរោត្តម រណឫទ្ធិ ហ៊ុន សែន

****